# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ : ៧៥ អនក្រ**

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារអន្តរក្រសួង
## រៀបចំសេចក្តីព្រាងច្បាប់ ស្តីពីការប្រយុទ្ធប្រឆាំងនឹងអំពើភេរវកម្ម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១.-**

បង្កើតក្រុមការងារអន្តរក្រសួងរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីការប្រយុទ្ធប្រឆាំងនឹងអំពើភេរវកម្ម ដែលមានសមាសភាពដូចខាងក្រោម :

១- ឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ប្រធាន
២- ឯកឧត្តមរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ១ រូប សមាជិក
៣- ឯកឧត្តមរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ១ រូប សមាជិក
៤- ឯកឧត្តមរដ្ឋលេខាធិការក្រសួងការពារជាតិ ១ រូប សមាជិក
៥- ឯកឧត្តមរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១ រូប សមាជិក

៦- ឯកឧត្តមរដ្ឋលេខាធិការក្រសួងយុត្តិធម៌ ១ រូប សមាជិក

៧- ឯកឧត្តមអគ្គទេសាភិបាលរងធនាគារជាតិកម្ពុជា ១ រូប សមាជិក

៨- ឯកឧត្តមអនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ១ រូប សមាជិក

**ប្រការ២.-**

ក្រុមការងារអន្តរក្រសួងនេះមានភារកិច្ចដូចខាងក្រោម :

- សិក្សាស្រាវជ្រាវអនុសញ្ញាអន្តរជាតិទាក់ទងទៅនឹងការប្រយុទ្ធប្រឆាំងអំពើភេរវកម្ម
- តាក់តែងសេចក្តីព្រាងច្បាប់ ស្តីពីការប្រយុទ្ធប្រឆាំងនឹងអំពើភេរវកម្ម អោយស្របទៅនឹងអនុសញ្ញាអន្តរជាតិទាក់ទងទៅនឹងការប្រយុទ្ធប្រឆាំងអំពើភេរវកម្ម ដែលកម្ពុជាបានចុះហត្ថលេខារួចហើយ
- ធ្វើទំនាក់ទំនងជាមួយបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីបំពេញភារកិច្ចអោយបានល្អប្រសើរ និងជំរុញការងារអោយមានដំណើរការទៅមុខបានឆាប់រហ័ស ។

**ប្រការ៣.-**

ក្រុមការងារអន្តរក្រសួងនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងយុត្តិធម៌ដើម្បីដំណើរការការងារ ។

សមាជិកក្រុមការងារអន្តរក្រសួង ត្រូវចូលរួមទទួលខុសត្រូវក្នុងក្របខ័ណ្ឌសមត្ថកិច្ច ភារកិច្ច ដែលបានចែងក្នុងប្រការ២ ខាងលើ និងត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធានក្រុមការងារ ។

**ប្រការ៤.-**

ក្រុមការងារអន្តរក្រសួងនេះ មានសិទ្ធិគ្រប់គ្រាន់ដើម្បីបង្កើតក្រុមការងារបច្ចេកទេសមួយ ជាជំនួយការដែលមានសមាជិកជាមន្ត្រីជំនាញជ្រើសរើសចេញមកពីក្រសួង និងស្ថាប័នពាក់ព័ន្ធខាងលើ ព្រមទាំងអ្នកឯកទេសបរទេស និងអន្តរជាតិមួយចំនួនទៀត ។

**ប្រការ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធព្រមទាំងសមាសភាពដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>ចម្លងជូន</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច និងឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ